**សម្ព័ន្ធទន្លេកម្ពុជា**

**The Rivers Coalition in Cambodia**

---

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## "របាយការណ៍ថ្មីរកឃើញថាផែនការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ខកខានក្នុងការលើកកម្ពស់នូវស្តង់ដារអនុវត្តប្រសើរបំផុត"

## ២០ សីហា ២០០៩

*ភ្នំពេញ* - ផែនការសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំនៅក្បែរចំនុចប្រសព្វនៃទន្លេសេសាន និងទន្លេស្រែពក ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង បានផ្តល់ឱ្យនូវចន្លោះប្រហោងនៃដំណើរការសិក្សាលទ្ធភាពគម្រោង ដែលពុំបានពិចារណាឱ្យបានត្រឹមត្រូវនូវផលប៉ះពាល់អវិជ្ជមានពីគម្រោងមកលើបរិស្ថាន និងសង្គម ព្រមទាំងតម្រូវការរបស់សហគមន៍រងផលប៉ះពាល់ដែលរស់នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមនៃទីតាំងបម្រុងរបស់ទំនប់ បានបកស្រាយក្នុងរបាយការណ៍ "*ការអនុវត្តប្រសើរបំផុតចំពោះការផ្តល់សំណង និងការតាំងលំនៅឋានថ្មី សម្រាប់ទំនប់ខ្នាតធំ: ករណីនៃគម្រោងផែនការវារីអគ្គិសនីសេសានក្រោម២ ក្នុងភាគឦសាននៃប្រទេសកម្ពុជា*" ទើបបោះពុម្ពផ្សាយក្នុងពេលថ្មីៗ។

របាយការណ៍ដែលបានរៀបចំដោយសម្ព័ន្ធទន្លេកម្ពុជា និពន្ធដោយអ្នកជំនាញខាងជលផល និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បណ្ឌិត Ian G. Baird បានចងក្រងនូវការព្រួយបារម្ភរបស់សហគមន៍ពាក់ព័ន្ធនឹងទំនប់សេសានក្រោម២ និងកំណត់ដំណើរការរៀបចំផែនការគ្រប់គ្រងបរិស្ថានរបស់ទំនប់ តាមរយៈទស្សនៈនៃស្តង់ដារ "អនុវត្តប្រសើរបំផុត" នៅថ្នាក់ភូមិ ជាតិ តំបន់ និងអន្តរជាតិ។ របាយការណ៍នេះបានរៀបចំដោយលើកឡើងនូវការព្រួយបារម្ភដែលបានថ្លែងដោយសង្គមស៊ីវិល និងសហគមន៍ក្នុងមូលដ្ឋានដែលថា ប្រសិនបើទំនប់សាងសង់ដោយពុំបានវាយតម្លៃតម្រូវការរបស់សហគមន៍ក្នុងមូលដ្ឋានឱ្យបានត្រឹមត្រូវ នោះអាចនឹងបណ្តាលបាត់បង់ជីវភាពរស់នៅ និងសហគមន៍រងផលប៉ះពាល់កាន់តែក្រីក្រ។ ទំនប់ដែលមានកម្ពស់ ៧៥ម៉ែត្រ ត្រូវបានរំពឹងថានឹងត្រូវលិចលង់ផ្ទៃដីនិងព្រៃឈើប្រមាណ ៣០.០០០ហិចតា ហើយ

ជាលទ្ធផលប្រជាជនប្រមាណ ៥០០០នាក់នឹងត្រូវផ្លាស់លំនៅ របាយការណ៍បានផ្តោតជាសំខាន់លើស្តង់ដារនៃការតាំងទីលំនៅថ្មី និងការផ្តល់សំណង ដើម្បីផ្តល់ជាអនុសាសន៍សម្រាប់ពិចារណាក្នុងដំណើរការសាងសង់ទំនប់ក្នុងប្រទេសកម្ពុជា។

ផ្អែកលើឯកសារផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងគម្រោង និងការពិភាក្សា ត្រូវបានធ្វើឡើងជាមួយសហគមន៍មូលដ្ឋានចំនួន ១១ ដែលអាចនឹងរងផលប៉ះពាល់ដោយសារទំនប់ របាយការណ៍នេះបានរកឃើញថា ក្រុមហ៊ុនវៀតណាមបានចាត់ឱ្យធ្វើការសិក្សាលទ្ធភាពទំនប់ ដោយក្រុមហ៊ុន PECC1 ខកខានមិនបានអនុវត្តសូម្បីតែស្តង់ដារអប្បបរមាសម្រាប់ការចូលរួម។ ការសិក្សាធ្វេសប្រហែសក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ទាំងនៅខ្សែទឹកខាងលើ និងប្រជាជនដែលរស់នៅក្នុងតំបន់អាងស្តុកបម្រុងនៃទំនប់ មិនត្រូវបានផ្តល់ជូនខ្លឹមសារនៃព័ត៌មានពាក់ព័ន្ធនឹងសក្តានុពលផលប៉ះពាល់នៃទំនប់នេះទេ។ ដំណើរការនេះមិនមានលក្ខណៈចូលរួម ហើយក៏មិនបានលើកកម្ពស់ដល់ការជជែកជាចំហរ និងប្រកបដោយអត្ថន័យផងដែរ។ ការចូលរួមជាសាធារណៈមិនបានពិចារណាលើទិដ្ឋភាពចម្បងបំផុតក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាមួយនឹងភស្តុតាងមកពីជុំវិញពិភពលោកដែលបានស្នើឡើងថាការចូលរួមកាន់តែច្រើនពីសាធារណៈជនក្នុងដំណើរការវាយតម្លៃ ដំណើរការនេះក៏កាន់តែមានភាពច្បាស់លាស់និងមានប្រយោជន៍។ ការចូលរួមជាសាធារណៈក៏អាចជួយធានាឱ្យមានការគាំទ្រដល់ការយល់ដឹង និងសហប្រតិបត្តការជារួមពីសហគមន៍ផងដែរ។

របាយការណ៍ *ការអនុវត្តប្រសើរបំផុត* កំពុងត្រូវបានរៀបចំដំណាលគ្នានឹងការបញ្ចប់ជាស្ថាពរនូវការពិនិត្យ *របាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងវារីអគ្គិសនីសេសានក្រោម២ ក្នុងខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា ខែតុលា ឆ្នាំ២០០៨* ដែលបានទទួលពីក្រសួងបរិស្ថាននៅចុងខែមិថុនា។ ការពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរៀបរាប់អំពីភាពខ្វះខាតពាក់ព័ន្ធផលប៉ះពាល់នៃទំនប់អាចនឹងកើតមានលើជីវភាព និងវប្បធម៌របស់សហគមន៍ក្នុងមូលដ្ឋាន កង្វះការចូលរួមពីសាធារណៈ ជាមួយអនុសាសន៍ចំពោះការអភិវឌ្ឍកាន់តែប្រកបដោយចីរភាពនៃបច្ចេកវិទ្យាថាមពលកកើតឡើងវិញជាជាងការសាងសង់ទំនប់វារីអគ្គិសនី។

របាយការណ៍ *ការអនុវត្តប្រសើរបំផុតចំពោះការផ្តល់សំណងនិងការតាំងលំនៅឋានថ្មី សម្រាប់ទំនប់ខ្នាតធំ* ដែលសម្ព័ន្ធទន្លេកម្ពុជាបានពិនិត្យមើល អាចស្វែងរកបាននៅលើគេហទំព័រ www.ngoforum.org.kh ។

សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការព្រួយបារម្ភរបស់សហគមន៍ចំពោះទំនប់វារីអគ្គិសនីសេសានក្រោម២ សូមទស្សនាវីដេអូផលិតដោយសហគមន៍ផ្ទាល់មានចំណងជើងថា *ការព្រួយបារម្ភរបស់យើងចំពោះទំនប់វារីអគ្គិសនីសេសានក្រោម២* តាមរយៈ

- ផ្នែកទី១ http://www.youtube.com/watch?v=8xVCjHXUyq4
- ផ្នែកទី២ http://www.youtube.com/watch?v=pbdYw3C8XcQ
- ផ្នែកទី៣ http://www.youtube.com/watch?v=TXMdaXkQlNY

សម្ព័ន្ធទន្លេកម្ពុជា គឺជាសម្ព័ន្ធនៃអង្គការសង្គមស៊ីវិលធ្វើការរួមគ្នាដើម្បីការពារនិងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅរបស់សហគមន៍ពឹងអាស្រ័យលើទន្លេក្នុងប្រទេសកម្ពុជា ហើយរួមបង្កើតឡើងដោយ បណ្តាញការពារទន្លេសេសាន ស្រែពក សេកុង អង្គការស្ម័គ្រចិត្តដើម្បីសង្គម អង្គការអភិរក្សនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា សមាគមថែរក្សាបរិស្ថាននិងវប្បធម៌ សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល និង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:


លោក ឈិត សំអាត នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
ទូរស័ព្ទ ០១២ ៩២៨ ៥៨៥ អ៊ីមែល samath@ngoforum.org.kh
លោក ទេព ប៊ុណ្ណារិទ្ធ នាយកប្រតិបត្តិ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌
ទូរស័ព្ទ ០១២ ៨៩៥ ៦២៤ អ៊ីមែល tep@cepa-cambodia.org
លោក មៀច មាន អ្នកសម្របសម្រួល បណ្តាញការពារទន្លេសេសាន ស្រែពក សេកុង
ទូរស័ព្ទ ០១១ ៧៥៨ ៩៧០ អ៊ីមែល sesan@online.com.kh
លោក ម៉ក់ សិទ្ធិរិទ្ធ នាយកប្រតិបត្តិ សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល
ទូរស័ព្ទ ០១២ ៩០៦ ២៧៩ អ៊ីមែល maksithirith@fact.org.kh